ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

នៅថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១០:០០ នាទីព្រឹក នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា** (HORINOUCHI Hidehisa) ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា នឹងចុះហត្ថលេខាលើលិខិតប្តូរសារ និងកំណត់ហេតុនៃការពិភាក្សា ស្តីពីការផ្តល់ហិរញ្ញប្បទានឥតសំណង ដែលមានទឹកប្រាក់សរុបចំនួន **៣ ៩៤២ លានយ៉េន** (**ប្រមាណ ៣៥ លានដុល្លារអាមេរិក**) សម្រាប់អនុវត្តគម្រោង **«សាងសង់ស្ពានបន្ទាន់ នៅតំបន់រងគ្រោះដោយសារទឹកជំនន់»** ។

ក្រោមគំពេងខាងលើនេះ ស្ពានចំនួន៥ នៅលើផ្លូវជាតិលេខ៧៣ នៅក្នុងខេត្តក្រចេះ និងស្ពានចំនួន២ទៀត នៅលើផ្លូវជាតិលេខ១១ នៅក្នុងខេត្តព្រៃវែង នឹងត្រូវបានសាងសង់សម្រាប់ជំនួសស្ពានដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន ដើម្បីពង្រឹងសមត្ថភាពដឹកជញ្ជូននៅតាមបណ្តោយផ្លូវជាតិទាំងពីរនេះ។

គួរកត់សំគាល់ថា ចាប់តាំងពីខែមេសា ឆ្នាំ២០១៧ កម្ពុជា បានទទួលជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុន ប្រហែល២៤៩លានដុល្លារអាមេរិក ក្នុងនោះរួមមាន ហិរញ្ញប្បទានឥតសំណងប្រមាណ៤០លានដុល្លារអាមេរិក សម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងការពារទឹកជំនន់ ព្រមទាំងការកែលំអរប្រព័ន្ធលូបង្ហូរទឹកនៅរាជធានីភ្នំពេញ និងកម្ចីសម្បទានដែលមានទឹកប្រាក់ប្រមាណ២០៩លានដុល្លារអាមេរិក សម្រាប់ការអភិវឌ្ឍចំណតផែកុងតឺន័រថ្មីនៅក្រុងព្រះសីហនុ។

ភ្នំពេញ ថ្ងៃទី ០២ ខែតុលា ឆ្នាំ២០១៧

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh